គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

# កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី០៨ ខែឧសភា ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ៨៣ ឆ្នាំទី២



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| - ប្រព័ន្ធសារព័ត៌មាននៅកម្ពុជានៅតែមានការរិតត្បិត | ១ |
| - ក្រុមប្រតិបត្តិការសឹករងខេត្តកំពង់ចាមរងការចោទប្រកាន់ពីថាមិនឆ្លុះឆ្លើយរបស់ដំណើរប្រជាពលរដ្ឋ | ២ |
| - សេចក្តីជូនដំណឹងពីការមិនចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ២ |
| - សេចក្តីជូនដំណឹងពីសិក្ខាសាលាថ្នាក់ដឹកនាំ | ៣ |



## ប្រព័ន្ធសារព័ត៌មាននៅកម្ពុជា នៅតែមានការរិតត្បិត

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការសិទ្ធិមនុស្សលីកាដូមានប្រសាសន៍ថា ពេលណាយើងនិយាយពីសេរីភាពគោងតែសេរីភាព ជាសេរីភាពពិតប្រាកដ មិនមែនសេរីភាពនៅក្នុងច្បាប់បានន័យថា អត់មានការគំរាមកំហែង និងបាញ់សំលាប់នោះទេ ។ លោកស្រីបានបន្តទៀតថានៅខែមិថុនា ឆ្នាំ២០០៨ មានការចាប់ខ្លួនលោក **ដាំ សិទ្ធិ** ចាងហ្វាងកាសែតមនសិការខ្មែរ ហើយក្រោយមកមានការបាញ់សំលាប់លោក **ឃឹម សំបូរ** អ្នកកាសែតមនសិការខ្មែរ និងកូនប្រុសរបស់លោកនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ ដូច្នេះបើមានការបាញ់សំលាប់ និងការចាប់ខ្លួនអ្នកកាសែតយកទៅដាក់នៅក្នុងពន្ធនាគារ យើងឃើញថាសេរីភាពខាងសារព័ត៌មានត្រូវបានបំបិទ ។ បើមានសេរីភាពលុះណាតែមានច្បាប់យើងឱ្យស្របទៅនឹងស្មារតីរបស់កតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាយើងបានឱ្យសច្ចាប័នតាំងពីឆ្នាំ១៩៩២ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សមានប្រសាសន៍ថា ប្រសិនបើយើងមើលអំពីបរិមាណនៃប្រព័ន្ធផ្សព្វផ្សាយពត៌មាននៅកម្ពុជាមិនធ្លាក់ចុះទេ ប៉ុន្តែបើនិយាយអំពីសិទ្ធិនៃការបញ្ចេញមតិមានការធ្លាក់ចុះច្រើន ។ អ្នកសារពត៌មាននៅតែទទួលរងនូវការប្តឹង ពីសមត្ថកិច្ច អ្នកមានអំណាចដោយប្រើប្រាស់ប្រព័ន្ធតុលាការក្បៀបសង្កត់ ។

លោក **កឹម សុខា** សមាជិករដ្ឋសភារបស់គណបក្សសិទ្ធិមនុស្សបានបញ្ជាក់បន្ថែមថា គណបក្សសិទ្ធិមនុស្សបានបើកទូលាយឱ្យអ្នកសារពត៌មានមានសេរីភាពពេញលេញ ដើម្បីទទួល និងចែកចាយពត៌មាន ។ សព្វថ្ងៃនេះអ្នកសារពត៌មាន មានបញ្ហាក្នុងការចែកចាយពត៌មាន និងការទទួលពត៌មាន ។

សូមបញ្ជាក់ថាចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់ឆ្នាំ ២០០៨ មានអ្នកសារពតិមានចំនួន១២នាក់ ហើយដែលរងរបួស និងស្លាប់ ។

## ក្រុមប្រតិបត្តិការសីករងខេត្តកំពង់ចាម រងការចោទប្រកាន់ពីថាបិទផ្លូវធ្វើ របស់ដំណើរប្រជាពលរដ្ឋ

ប្រជាពលរដ្ឋនៅភូមិមួយចំនួនក្នុងឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម បានចោទទាហានសីករងស្រុកពញាក្រែកថាបានឈូសឆាយផ្លូវសហគមន៍ដាំកៅស៊ូ ហើយអ្នកស្រុកនៅទីនោះមិនអាចបររទេះគោក្របី បើកបររថយន្តឆ្លងកាត់ផ្លូវសហគមន៍បានឡើយ ។

ប្រជាពលរដ្ឋម្នាក់នៅភូមិកោងកាងទី១ ក្នុងឃុំកោងកាងបាននិយាយថា ផ្លូវនោះជាផ្លូវសហគមន៍ក្រាលគ្រួសក្រហម មានប្រវែង៣គ.ម ដែលប្រជាពលរដ្ឋឆ្លងកាត់ពីភូមិមួយទៅភូមិមួយដើម្បីដឹកកសិផលឆ្លងកាត់ ។ ប៉ុន្តែចាប់តាំងពីអំឡុងឆ្នាំ២០០៣រហូតមកដល់ពេលនេះប្រជាពលរដ្ឋ មានការខ្លាចរអា មិនហ៊ានតវ៉ា ចំណែករដ្ឋអំណាចក៏មិនដោះស្រាយឱ្យដែរ ។ អ្នកភូមិរូបនោះបានបន្តទៀតថា ដីដាំកៅស៊ូនោះមួយផ្នែកជាកម្មសិទ្ធិរបស់ទាហ៊ានសីករងនោះមែននោះដែរ ។ កាលពីមុននេះផ្លូវមួយខ្សែនោះ ប្រជាពលរដ្ឋនៅភូមិកោងកាងទី១ ភូមិត្រពាំងព្រៃ ភូមិឡូ ភូមិត្រពាំងកង ឆ្លងកាត់ដឹកសិផលយកទៅលក់ដូរ ។ លោក **ប៉ុច ទូច** មេឃុំកោងកាងបានយកបញ្ជាក់ថា រហូតមកដល់ពេលនេះហាក់ដូចជាមិនទាន់ឃើញមានហេតុការណ៍ អ្វីកើតឡើងខ្លាំងក្លានៅឡើយទេ ។ រឿងនេះដែរលោកក៏បានធ្វើរបាយការណ៍ទៅថ្នាក់លើហើយ ប៉ុន្តែថ្នាក់លើកំពុងចុះទៅសិក្សា ។ លោកថា ការដាំចំការកៅស៊ូ បានប៉ះពាល់ដល់ដីប្រជាពលរដ្ឋប្រមាណ២-៣ហិកតាប៉ុណ្ណោះ ។

ចំណែកប្រជាពលរដ្ឋមានសិទ្ធិប្តឹង ទោះបីអ្នកនោះមានអំណាចធំយ៉ាងណាក៏ដោយ ក៏ត្រូវតែបើកផ្លូវឱ្យប្រជាពលរដ្ឋ ពីព្រោះជាទ្រព្យសាធារណៈរបស់រដ្ឋដែលច្បាប់បានហាមឃាត់ ។

អ្នកភូមិកោងកាងទី២ បានរៀបរាប់ថា ផ្លូវសហគមន៍នោះប្រជាពលរដ្ឋអាចដើរជិះកងម៉ូតូបាន ប៉ុន្តែបើកគោយន្ត រថយន្ត រទេះគោ ក្របីមិនបានទេ ។ ចំពោះទំហំដីដាំកៅស៊ូស្វាយចន្ទីមានទំហំប្រហែល ១០ហិកតា ។

យើងមិនទាក់ទងសុំការបំភ្លឺពីលោក **កែវ ចន្ទី** ប្រធានប្រតិបត្តិការសីករង ស្រុកពញាក្រែកបានទេនៅថ្ងៃនេះ ។

## សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានគណបក្សសិទ្ធិមនុស្ស មានកិត្តិយសជំរាបជូនដល់សកម្មជន ជាពិសេសរចនាសម្ព័ន្ធថ្នាក់ខេត្ត ក្រុង រាជធានី ស្រុក ខណ្ឌ ឃុំ សង្កាត់ ទាំងអស់នៃគណបក្សសិទ្ធិមនុស្ស ឱ្យបានជ្រាបថា :

១. នៅក្នុងការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង រាជធានី ស្រុក ខណ្ឌ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែឧសភាខាងមុខនេះ គណបក្សសិទ្ធិមនុស្ស សម្រេចមិនដាក់បេក្ខភាពរបស់ខ្លួនចូលរួមក្នុងការបោះឆ្នោតនេះទេ ព្រោះការបោះឆ្នោតអសកលបែបនេះ គឺមានប្រយោជន៍តែគណបក្សណាដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយតែប៉ុណ្ណោះ ។

២. ក្នុងករណីមានអាជ្ញាធរ ឬគណបក្សនយោបាយណាមួយអញ្ជើញសកម្មជន ឬថ្នាក់ដឹកនាំមូលដ្ឋានរបស់គណបក្សសិទ្ធិមនុស្សយើងឱ្យចូលរួមប្រជុំអ្វីមួយ សូមមេត្តាផ្តល់ដំណឹង និងទទួលការអនុញ្ញាតពីអគ្គលេខា

ធិការដ្ឋានរបស់គណបក្សសិទ្ធិមនុស្សជាមុន មុននឹងសម្រេចចូលរួម ឬមិនចូលរួម ។

៣. លេខទូរស័ព្ទដែលត្រូវទាក់ទងជាមួយអគ្គលេខាធិការដ្ឋានគណបក្សសិទ្ធិមនុស្ស ជារៀងរាល់ថ្ងៃ គឺមានលេខ : ០១៧ ៣០៣ ៩០០ ។

អាស្រ័យហេតុនេះ សូមសកម្មជននៃគណបក្សសិទ្ធិមនុស្សទាំងអស់មេត្តាជ្រាប និងប្រុងប្រយ័ត្ននូវឧបាយកលបន្លំបោកប្រាស់គ្រប់រូបភាពពីបុគ្គល ឬក៏គណបក្ស ដែលមានបំណងអាក្រក់ចង់បំផ្លាញចលនាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាយើង ។

សូមអរគុណ !

## សូមជម្រាបជូន

## លោកប្រធាន
## ឬតំណាងគណៈកម្មាធិការប្រតិបត្តិខេត្ត
## នៃគណបក្សសិទ្ធិមនុស្ស

កម្មវត្ថុ : សិក្ខាសាលាពង្រឹងគណបក្សថ្ងៃទី២២,២៣ និង២៤ ខែឧសភា ឆ្នាំ២០០៩នៅស្នាក់ការកណ្តាល ផ្ទះលេខ ៧២-៧៤ ផ្លូវ៥៩៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

សេចក្តីដូចបានជម្រាបជូន ក្នុងកម្មវត្ថុខាងលើ អគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស មានកិត្តិយសជម្រាបលោកថា ដើម្បីពង្រឹងសមត្ថភាពថ្នាក់ដឹកនាំគណបក្សខេត្ត-រាជធានីអោយមានជំហរ និងទស្សនៈនយោបាយរឹងមាំ និងចេះរៀបចំការងារកាន់តែល្អប្រសើរ គណបក្សនឹងរៀបចំសិក្ខាសាលាមួយដែលបាន បញ្ជាក់ខាងលើ ។ សិក្ខាកាមដែលត្រូវអញ្ជើញមកនឹងត្រូវទទួលបានការឧបត្ថម្ភអាហារ ការស្នាក់នៅ( ក្នុងស្នាក់ការគណបក្ស) និងសោហ៊ុយធ្វើដំណើរទៅមក រួមទាំងឯកសារដែលត្រូវចែកជូននៅពេលសិក្សាផងដែរ ។

អាស្រ័យហេតុនេះ សូមលោកប្រធាន ឬតំណាងចាត់បញ្ជូនសមាជិកប្រតិបត្តិ២រូប (ប្រធាន និងអនុប្រធាន ឬលេខាធិការ...) មកចូលរួមកុំបីខាន ។

| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |

**.............................................................................!**